ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍បន្ទាយប្រិយ

## សម្រាប់រយៈពេល០៣ឆ្នាំ (ខែកុម្ភៈ ឆ្នាំ២០២២-ខែធ្នូ ឆ្នាំ២០២៤)

| | |
|---|---|
| សហគមន៍នេសាទ | ៖ បន្ទាយប្រិយ |
| ភូមិ | ៖ បន្ទាយប្រិយ |
| ឃុំ | ៖ អណ្តូងថ្ម |
| ស្រុក | ៖ ព្រៃនប់ |
| ខេត្ត | ៖ ព្រះសីហនុ |

ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១

## មាតិកា

**១.ស្ថានភាពទូទៅ** ............ ១
**២.អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម** ............ ១
ក.ប្រជាពលរដ្ឋ............ ១
ខ.មុខរបរ............ ២
**៣.កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍** ............ ២
ក.ទីតាំង............ ២
ខ.ដែននេសាទ............ ២
គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស............ ៣
ឃ. ធនធានជលផល............ ៣
១.ប្រភេទត្រី............ ៤
២.ប្រភេទវារីសត្វ............ ៤
៣.ប្រភេទរុក្ខជាតិព្រៃកោងកាង និងវារីរុក្ខជាតិសមុទ្រ............ ៤
**៤.ការធ្វើនេសាទ** ............ ៤
ក.អ្នកនេសាទ............ ៤
ខ.ឧបករណ៍នេសាទ............ ៤
គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ............ ៦
**៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** ............ ៦
ក.ទស្សនៈវិស័យ............ ៦
ខ.គោលបំណង............ ៦
គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍............ ៦
គ.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ............ ៦
គ.២.ផែនការចុះល្បាត............ ៧
គ.៣.ផែនការរៀបចំកន្លែងអភិរក្ស............ ៨
គ.៤.ផែនការគ្រប់គ្រងព្រៃកោងកាង............ ៩
គ.៥.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម............ ១០
គ.៦.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទ............ ១១
គ.៧.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ............ ១២
គ.៨.ផែនការផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ............ ១២
គ.៩.ផែនការបង្កើតស្នាក់ការ និងបណ្ណាល័យសហគមន៍នេសាទ............ ១៣
គ.១០.ផែនការថវិការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍............ ១៣

ឃ.យុទ្ធសាស្ត្រ ............................................................................................................១៤

**៦.ឧបសម្ពន្ធ**

ឧបសម្ពន្ធ ៖ តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឆ្នាំ២០២២-២០២៤..............................១៥

តារាងកម្មវិធីការងារសម្រាប់សហគមន៍នេសាទក្នុងរយៈពេល០៣ឆ្នាំ២០២២-២០២៤................១៨

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍បន្ទាយព្រិយ

## ១.ស្ថានភាពទូទៅ

នៅឆ្នាំ២០០០រដ្ឋបាលជលផលបានធ្វើកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងវិស័យជលផល ដើម្បីឱ្យសមស្របជាមួយគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការដែលមានក្នុងជាយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដោយផ្តោតលើការកាត់បន្ថយភាពក្រីក្រតាមរយៈការផ្ទេរសិទ្ធិអំណាចដល់ប្រជាពលរដ្ឋដែលរស់ជនបទ ដើម្បីចូលរួមគ្រប់គ្រងធនធានជលផលនៅក្នុងមូលដ្ឋានរបស់ខ្លួនប្រកបដោយចីរភាព និងសមធម៌តាមបែបសហគមន៍នេសាទក្នុងគោលបំណងទទួលផលប្រយោជន៍ និងធ្វើឱ្យធនធានជលផលប្រសើរឡើងនៅមូលដ្ឋានរបស់ខ្លួន។ ភូមិ**បន្ទាយព្រិយ** ត្រូវបានរៀបចំសហគមន៍នេសាទដោយមានការចូលរួមយ៉ាងកុះករពីប្រជាពលរដ្ឋមូលដ្ឋាន និងបានទទួលការគាំទ្រថវិកាពីរដ្ឋបាលជលផល និងមានកិច្ចសហការពីអាជ្ញាធរដែនដី។ សហគមន៍នេសាទ**បន្ទាយព្រិយ** ត្រូវបានបង្កើតឡើងដោយមហាសន្និបាតលើកដំបូងនៅថ្ងៃទី២៦ខែឧសភា ឆ្នាំ២០០៤ ដោយបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រកាសទទួលស្គាល់នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ និងបានរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍លើកទី១នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១១ ហើយបានរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍លើកទី២ ដែលនឹងអនុវត្តចាប់ពីខែកុម្ភៈ ឆ្នាំ២០២២ ដល់ ខែធ្នូ ឆ្នាំ២០២៤។

គណៈកម្មការសហគមន៍នេសាទ ត្រូវបានបោះឆ្នោតដែលមានសមាជិកគណៈកម្មការសហគមន៍នេសាទមានចំនួន១១នាក់ក្នុងនោះស្ត្រី០៣នាក់ ព្រមទាំងបានអនុវត្តតួនាទី និងភារៈកិច្ចរបស់ខ្លួនដែលស្របតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀងកន្លែងនេសាទ និងផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍។ ទន្ទឹមនឹងនេះ គណៈកម្មការសហគមន៍នេសាទបានកសាងសមត្ថភាពតាមរយៈការចូលរួមបណ្តុះបណ្តាល សិក្ខាសាលា ប្រជុំការងារ ទស្សនៈកិច្ចសិក្សា និងរៀនសូត្រតាមឯកសារផ្សេងៗ។

គណៈកម្មការសហគមន៍នេសាទនេះបានរៀបចំសកម្មភាពសំខាន់ៗ ដើម្បីឱ្យសហគមន៍នេសាទមានផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍សម្រាប់អនុវត្ត និងបង្កលក្ខណៈឱ្យសហគមន៍នេសាទ អាចស្វែងរកថវិកាអនុវត្តការងារសកម្មភាពរបស់ខ្លួន ក្នុងការជួយដល់ការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទសហគមន៍ ព្រមទាំងប្រជាពលរដ្ឋមូលដ្ឋាន ទទួលបានផលប្រយោជន៍ពីការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរ។

## ២.អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក.ប្រជាពលរដ្ឋ

សហគមន៍នេសាទស្ថានភាពដូចជា៖

- ផ្អែកតាមការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅក្នុងសហគមន៍**បន្ទាយព្រិយ**បានបង្ហាញថា គ្រួសារដែលស្ថិតក្នុងក្រីក្រ-២មានចំនួន២៥នាក់ ក្នុងស្ត្រីមានចំនួន០៧នាក់ និងប្រជាពលរដ្ឋក្រីក្រ-១មានចំនួន០៧នាក់ ក្នុងនោះស្ត្រីមានចំនួន០៣នាក់
- ស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមានចំនួន១៣នាក់
- បុរសពោះម៉ាយក្នុងសហគមន៍នេសាទមានចំនួន១៧នាក់
- ជនពិការក្នុងសហគមន៍នេសាទមានចំនួន០៥នាក់ ក្នុងនោះស្ត្រីមានចំនួន០៣នាក់
- ចាស់ជរាក្នុងសហគមន៍នេសាទមានចំនួន៤៥នាក់ ក្នុងនោះស្ត្រីមានចំនួន៣៨នាក់

- អ្នកមានជម្ងឺរាំរ៉ៃក្នុងសហគមន៍នេសាទមានចំនួន០៣នាក់
- តាមរបាយការណ៍របស់ក្រុមប្រឹក្សាឃុំ នៅក្នុងសហគមន៍នេសាទបានបង្ហាញថាចំនួន១៨នាក់ដែលមិនចេះអក្សរក្នុងនោះស្ត្រីមានចំនួន០៦នាក់។

**ខ.មុខរបរ**

តាមរបាយការណ៍របស់ក្រុមប្រឹក្សាឃុំបានបញ្ជាក់ថា ប្រជាពលរដ្ឋក្នុងសហគមន៍នេះពឹងផ្អែកលើការធ្វើនេសាទ វារីវប្បកម្ម ការធ្វើស្រែ និងការចិញ្ចឹមសត្វ។ ការគាំទ្រមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ ជាសកម្មភាពចំបងដែលជួយពង្រីកមុខរបរដល់ប្រជានេសាទនៅក្នុងសហគមន៍ ជាពិសេស បានជួយកាត់បន្ថយសម្ពាធនៃការធ្វើអាជីវកម្មលើធនធានជលផលហួសកំរិត។ រដ្ឋបាលជលផល និងអង្គការដៃគូអភិវឌ្ឍន៍បានជួយបណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមត្រីលក្ខណៈគ្រួសារ និងការចិញ្ចឹមសត្វ ព្រមទាំងការចិញ្ចឹមជីវិតផ្សេងទៀតដល់សមាជិកសហគមន៍នេសាទ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឱ្យមានការរីកចំរើន។

ពេលបច្ចុប្បន្ន នៅក្នុងសហគមន៍នេសាទ**បន្ទាយប្រិយ** ប្រជាពលរដ្ឋមានស្ថានភាពនៃការចិញ្ចឹមជីវិត និងមុខរបរសំខាន់ៗរួមមាន៖

| ល.រ | ប្រភេទមុខរបរ | ចំនួនគ្រួសារ | សំគាល់ |
|---|---|---|---|
| ១ | អ្នកមានមុខរបរធ្វើនេសាទ | ៣៦៥ | ជាមុខរបរចំបង |
| ២ | អ្នកធ្វើស្រែ និងអ្នកចិញ្ចឹមសត្វ | ៣១០ | |
| ៣ | ធ្វើវារីវប្បកម្ម | ២១ | |
| ៤ | ដាំបន្លែ | ៦៧ | |
| ៥ | អ្នកលក់ដូរ | ៦៥ | |
| ៦ | កែច្នៃផលនេសាទសម្រាប់គ្រួសារ | ២១៥ | |
| ៧ | ជាងផ្ទះ | ០៧ | |
| ៨ | កម្មករចល័ត | ៦៧ | |

## ៣.កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទ

**ក.ទីតាំង**

សហគមន៍នេសាទ**បន្ទាយប្រិយ** មានទីតាំងស្ថិតនៅតាមវាយស្រែ ព្រៃកទឹកសាបនិងតំបន់ឆ្នេរ ដែលជាដែននេសាទសមុទ្រសាធារណៈរបស់រដ្ឋ។ សហគមន៍នេសាទនេះ ត្រូវបានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ដែលប្រកាសទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ដូចនេះ សហគមន៍នេសាទ មានព្រំប្រទល់ជាប់នឹង៖

- ខាងជើងទល់នឹងសង្កាត់សំរុង
- ខាងត្បូងទល់សង្កាត់នឹងទួលទទឹង
- ខាងកើតជាប់នឹងសមុទ្រ
- ខាងលិចទល់ជាប់ភ្នំចំណោទតាមាស។

**ខ.ដែននេសាទ**

កន្លែងនេសាទសហគមន៍នេសាទ**បន្ទាយប្រិយ** មានវិសាលភាពនៅលើដែននេសាទសមុទ្រដែលមានកន្លែងនេសាទទំហំ២២២៩ហិកតា ហើយមានកន្លែងអភិរក្សពូជត្រី និងស្មៅសមុទ្រសំខាន់ៗ។

កន្លែងនេសាទសហគមន៍ បានផ្តល់នូវលក្ខណៈងាយស្រួលដល់ការរស់នៅរបស់សហគមន៍មូលដ្ឋាន និងការធ្វើនេសាទសមុទ្ររបស់អ្នកនេសាទនៅក្នុងសហគមន៍ ក៏ដូចជាអ្នកមកពីខាងក្រៅសហគមន៍ ជាពិសេសកន្លែងនេសាទនេះមានអំណោយផលល្អដល់ការរស់នៅរបស់ពពួករុក្ខជាតិ ហើយជាចំណី និងជម្រកពងកូនរបស់មច្ឆា សត្វស្លាប និងសត្វល្មូនគ្រប់ប្រភេទ។ កន្លែងនេសាទសហគមន៍ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះ បឹង ព្រែក អូរ ឬប្រឡាយ | ឯកតា | ប្រវែង/ទំហំ/ចំនួន | រដូវនេសាទ |
|---|---|---|---|---|
| ១ | ព្រែកស្រមោច | ម៉ែត្រ | ២ ៥០០ | ពេញមួយឆ្នាំ |
| ២ | អាងបន្ទាយប្រិយ | ហិកតា | ០៤ | ពេញមួយឆ្នាំ |
| ៣ | បៀរ | បៀរ | ៥០ | ពេញមួយឆ្នាំ |
| ៤ | ព្រៃកោងកាង | ហិកតា | ២៨០ | ពេញមួយឆ្នាំ |
| ៥ | ព្រែកបឹងចាក | ម៉ែត្រ | ៧០០០ | ពីខែ០៥ ដល់ ខែ១២ |
| ៦ | ប្រឡាយបន្ទាយប្រិយ | ម៉ែត្រ | ៨០០០ | ពីខែ០៥ ដល់ ខែ១២ |
| ៧ | ប្រឡាយទទឹង | ម៉ែត្រ | ១៥០០ | ពីខែ០៥ ដល់ ខែ១២ |
| ៨ | អូរធំ | ម៉ែត្រ | ១៥០០ | ពីខែ០៥ ដល់ ខែ១២ |

**គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

កន្លែងដែលអាចមានលទ្ធភាពបង្កើតកន្លែងអភិរក្សគឺ **ព្រែកស្រមោច និងព្រែកបឹងចាក**។ ព្រែកស្រមោចគឺ ជាកន្លែងមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជ ផ្កាថ្ម និងព្រៃកោងកាងដែលមានទំហំប្រហែល១០ហិកតា និងកន្លែងមានគ្រែងឈាមដែលមានទំហំប្រហែល០៥ហិកតា ហើយជាកន្លែងមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជ ផ្កាថ្ម គ្រែងឈាម។ ដោយឡែក ចំនុចកោះព្រែកបឹងចាកមានព្រៃកោងកាងទំហំប្រហែល៥០ហិកតាដែលសំបូរត្រីមេពូជ ផ្កាថ្ម ងាវ។ល។ កន្លែងអភិរក្សត្រីមេពូជទាំងនេះ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះកន្លែងអភិរក្ស | ទំហំជាហិកតា | ការអភិរក្ស |
|---|---|---|---|
| ១ | ព្រែកស្រមោច | ១០ | អភិរក្សត្រីមេពូជ ក្តាម ផ្កាថ្ម |
| ២ | ព្រែកបឹងចាក | ៥០ | អភិរក្សត្រីមេពូជ ផ្កាថ្ម |
| ៣ | កន្លែងអភិរក្សគ្រែងឈាម | ០៥ | អភិរក្សគ្រែងឈាម |

**ឃ.ធនធានជលផល**

នៅក្នុងប្រទេសកម្ពុជា ធនធានជលផលបានដើរតួនាទីយ៉ាងសំខាន់ក្នុងសន្តិសុខស្បៀង ដោយឡែកត្រីអាចផ្តល់ជាអាហារដល់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ។ តាមការបង្ហាញពីសហគមន៍បានឱ្យដឹងថាពេលបច្ចុប្បន្ន ធនធានជលផលក្នុងសមុទ្រមិនមានការកើនឡើងទេ ដោយសារមានការប្រែប្រួលអាកាសធាតុ។ ផ្អែកតាមការអង្កេតរបស់ក្រុមការងារ និងសមាជិកសហគមន៍ ស្ថានភាពធនធានជលផលមានដូចខាងក្រោម៖

ឃ.១.ប្រភេទត្រីសមុទ្រៈ

ក្នុងសហគមន៍នេសាទនេះ មានប្រភេទត្រីដូចជាៈ ត្រីឆ្លង់ ត្រីក្បក ត្រីប្រកុង ត្រីអាំងកឺយ ត្រីចង្កោមបី ត្រីដំឡូង ត្រីប្លាធូ ត្រីក្តចិន ត្រីស្តុងក្រហម ត្រីថ្មោង ត្រីត្រសក់ ត្រីឆ្លាម ត្រីកាវ៉ាវ ត្រីប្រម៉ា ត្រីកិ ត្រីកន្ទង ត្រីកាម៉ុង ត្រីក្បាលឡាន ត្រីអណ្តែងប៉ុយ ត្រីកន្តាំង ត្រីកន្ទុយរឹង ត្រីកាបាស ត្រីបបែល ត្រីឆ្លាត ត្រីក្អុក ត្រីបាលង្គ។ល។

ឃ.២.ប្រភេទវារីសត្វសមុទ្រ

ក្នុងសហគមន៍នេសាទនេះ មានប្រភេទវារីសត្វដូចជាៈ បង្កង បង្គា ក្តាមសេះ ក្តាមថ្ម ក្តាមជ័រ មឹក គ្រែងឈាម ងាវភក់ ហូល ងាវស បង្កងប៉ាក អណ្តើក កន្ទាយ បាលង្ក័កាស កញ្ច អន្ទង់។ល។

ឃ.៣.ប្រភេទរុក្ខជាតិព្រៃកោងកាង និងវារីរុក្ខជាតិ

នៅក្នុងសហគមន៍នេសាទនេះ មានព្រៃកោងកាង និងវារីរុក្ខជាតិដូចជាៈ ផ្កាថ្ម ស្មៅសមុទ្រ និងព្រៃកោងកាង។

## ៤.ការធ្វើនេសាទ

តាមការសិក្សា និងប្រមូលទិន្នន័យពីក្រុមប្រឹក្សាឃុំ ភូមិ និងសហគមន៍បានបង្ហាញថា ចំនួនអ្នកដែលពាក់ព័ន្ធក្នុងការធ្វើនេសាទក្នុងកន្លែងនេសាទសហគមន៍មានដូចខាងក្រោមៈ

### ៤.ក.អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន៣៧៥នាក់ ក្នុងនោះស្ត្រីមានចំនួន៩៥នាក់។
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន៤៤៧នាក់ ក្នុងនោះស្ត្រីមានចំនួន១៧៥នាក់។
- តាមការប៉ាន់ស្មានអ្នកនេសាទដែលមកពីខាងក្រៅ ហើយមិនមែនជាសមាជិកដែលជាសហគមន៍មានប្រហែល១២៣គ្រួសារ ក្នុងនោះស្ត្រីមានចំនួន២៥នាក់។

### ៤.ខ.ឧបករណ៍នេសាទ

ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទដែលប្រើប្រាស់មានដូចជាៈ

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ/ចំនួន | រដូវនេសាទ |
|---|---|---|---|---|
| ១ | មងត្រីក្បក | ម៉ែត្រ | ៩០ | ពេញមួយឆ្នាំ |
| ២ | មងត្រីតាវ៉ | ម៉ែត្រ | ៣៥០ | ពេញមួយឆ្នាំ |
| ៣ | លបក្តាមសេះ | លប | ២៥០ | ពេញមួយឆ្នាំ |
| ៤ | លបក្តាម | លប | ៥០០ | ពីខែ១២ ដល់ ខែ០១ |
| ៥ | សន្ទូចត្រីក្អុក | ផ្លែ | ១៥០ | ពីខែ០៤ ដល់ ខែ០៧ |
| ៦ | មងក្តាម | ម៉ែត្រ | ១៧៥ | ពីខែ១១ ដល់ ខែ០១ |
| ៧ | មងត្រីកន្តាំង | ម៉ែត្រ | ១៥០ | ពីខែ០៤ ដល់ ខែ០៧ |
| ៨ | សន្ទូចត្រីអន្តែងប៉ុយ | ផ្លែ | ១៥០ | ពីខែ០៤ ដល់ ខែ០៧ |
| ៩ | មងត្រីឆ្លុង | ម៉ែត្រ | ៣៥០ | ពីខែ១០ ដល់ ខែ០៤ |
| ១០ | សន្ទូចបបែល | ផ្លែ | ៥០០ | ពីខែ០៤ ដល់ ខែ០៧ |
| ១១ | ឈិបរុញដោយដៃ | គ្រឿង | ៣ម ទៅ៥ម | ពីខែ០១ ដល់ ខែ១២ |

ចំពោះការប្រើប្រាស់ឧបករណ៍នេសាទសមុទ្រគឺ ផ្អែកតាមប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ប្រកាសលេខ៣១៩ ប្រក.កសក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ ។

| ល.រ | ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|---|
| ១ | ទូកម៉ាស៊ីន | ១០៥ | ៧០០ | ៦ ដល់ ១៣ |
| ២ | ទូកចែវ | ៤៥ | ៥០ | |

ឧបករណ៍នេសាទ និងកាណូតរបស់អ្នកខាងក្នុងសហគមន៍នេសាទតែមិនមែនជាសមាជិកមានដូចជា៖

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|
| ១ | មងត្រីក្បក | ម៉ែត្រ | ៩០ | ពេញមួយឆ្នាំ |
| ២ | មងត្រីតាវរ | ម៉ែត្រ | ៣៥០ | ពេញមួយឆ្នាំ |
| ៣ | លបក្តាមសេះ | លប | ២៥០ | ពេញមួយឆ្នាំ |
| ៤ | លបក្តាម | លប | ៥០០ | ពីខែ១២ ដល់ ខែ០១ |
| ៥ | សន្ទូចត្រីក្អក | ថ្លៃ | ១៥០ | ពីខែ០៤ ដល់ ខែ០៧ |
| ៦ | មងក្តាម | ម៉ែត្រ | ១៧៥ | ពីខែ១១ ដល់ ខែ០១ |
| ៧ | មងត្រីកន្តាំង | ម៉ែត្រ | ១៥០ | ពីខែ០៤ ដល់ ខែ០៧ |
| ៨ | សន្ទូចត្រីអន្ទែងប៉ុយ | ថ្លៃ | ១៥០ | ពីខែ០៤ ដល់ ខែ០៧ |
| ៩ | មងត្រីឆ្តុង | ម៉ែត្រ | ៣៥០ | ពីខែ១០ ដល់ ខែ០៤ |
| ១០ | សន្ទូចបបែល | ថ្លៃ | ៥០០ | ពីខែ០៤ ដល់ ខែ០៧ |
| ១១ | ឈិបរុញដោយដៃ | គ្រឿង | ៣ម ទៅ៥ម | ពីខែ០១ ដល់ ខែ១២ |

| ល.រ | ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|---|
| ១ | ទូកម៉ាស៊ីន | ៣២ | ៧០០ | ៦ ដល់ ១៣ |
| ២ | ទូកចែវ | ២៣ | ១០០ | |

ឧបករណ៍នេសាទ និងកាណូតរបស់អ្នកមិនមែនជាសមាជិក ដែលមកពីក្រៅសហគមន៍នេសាទ មានដូចជា៖

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ/ចំនួន | រដូវនេសាទ |
|---|---|---|---|---|
| ១ | លបក្តាមសេះ | លប | ២៥០ | ពេញមួយឆ្នាំ |
| ២ | លបក្តាម | លប | ៥០០ | ពីខែ១២ ដល់ ខែ០១ |
| ៣ | មងក្តាម | ម៉ែត្រ | ១៧៥ | ពីខែ១១ ដល់ ខែ០១ |
| ៤ | មងត្រីឆ្តុង | ម៉ែត្រ | ៣៥០ | ពីខែ១០ ដល់ ខែ០៤ |
| ៥ | ឈិបរុញដោយដៃ | គ្រឿង | ៣ម ទៅ៥ម | ពីខែ០១ ដល់ ខែ១២ |

| ប្រភេទទូកកាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីន | ៥០ | ១០០០ | ៦ ដល់ ១៣ |

**គ.ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ**

| ល.រ | ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គក្រ) | | |
|---|---|---|---|---|
| | | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ១ | ត្រីគ្រប់ប្រភេទ | ១៥៧ | ១៧៨ | ៣៣៥ |
| ២ | បង្គា | ១២៥ | ២០៥ | ៣៣០ |
| ៣ | ក្ដាម | ៩៩ | ១១៧ | ២១៦ |
| ៤ | មឹក ខ្យង និងគ្រែងឈាម | ៨៥ | ៩៧ | ១៨២ |
| សរុប | | ៤៦៦ | ៥៩៧ | ១០៦៣ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

**ក.ទស្សនៈវិស័យ**

សហគមន៍នេសាទនេះ មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

**ខ.គោលបំណង**

- ចូលរួមគ្រប់គ្រងដែននេសាទសមុទ្រជាកន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទទំនាបលិចទឹក នៅរដូវទឹកជោរក្នុងព្រៃកោងកាង និងកន្លែងអន្លង់អភិរក្ស។
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌។
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទតាមរយៈការអភិវឌ្ឍន៍ចំរុះ។
- ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ច្បាស់ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

**គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**

**គ.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ:**

**គោលបំណង**

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍គឺ រៀបចំឡើងដោយបានគិតគូរអំពីប្រភេទដែននេសាទ ប្រភេទទំហំ ប្រវែងចំនួនឧបករណ៍នេសាទចំនួនអ្នកនេសាទ រដូវនេសាទ និងការប៉ាន់ប្រមាណផលស្តុកដែលមាននៅក្នុងដែននេសាទ ដោយធ្វើយ៉ាងណាមិនឱ្យការធ្វើនេសាទលើសពីតម្រូវការធនធានជលផលដែលមានក្នុងកន្លែងសហគមន៍នេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទ ត្រូវបានរៀបចំឡើង ដូចមានក្នុងតារាងខាងក្រោមៈ

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ/ចំនួន | រដូវនេសាទ |
|---|---|---|---|---|
| ១ | មងត្រីក្បក | ម៉ែត្រ | ៩០ | ពេញមួយឆ្នាំ |
| ២ | មងត្រីតាវ | ម៉ែត្រ | ៣៥០ | ពេញមួយឆ្នាំ |
| ៣ | មងត្រីផ្ទោង | ម៉ែត្រ | ១៥០ | ពេញមួយឆ្នាំ |
| ៤ | លបក្ដាមសេះ | លប | ២៥០ | ពេញមួយឆ្នាំ |
| ៥ | លបក្ដាម | លប | ៥០០ | ពីខែ១២ ដល់ ខែ០១ |
| ៦ | មងបង្គា | ម៉ែត្រ | ១៥០ | ពីខែ១២ ដល់ ខែ០១ |
| ៧ | មងក្ដាម | ម៉ែត្រ | ១៧៥ | ពីខែ១១ ដល់ ខែ០១ |
| ៨ | មងត្រីការម៉ុង | ម៉ែត្រ | ២៥០ | ពីខែ០៤ ដល់ ខែ០៦ |
| ៩ | មងត្រីគូន | ម៉ែត្រ | ៣០ | ពីខែ០៩ ដល់ ខែ១២ |
| ១០ | មងត្រីឆ្លង | ម៉ែត្រ | ៣៥០ | ពីខែ១០ ដល់ ខែ០៤ |
| ១១ | សន្ទូចបបែល | ផ្លែ | ៥០០ | ពីខែ០៤ ដល់ ខែ០៧ |
| ១២ | សន្ទូចត្រីក្អក | ផ្លែ | ១៥០ | ពីខែ០៤ ដល់ ខែ០៧ |
| ១៣ | សន្ទូចត្រីអន្ទែងប៉ុយ | ផ្លែ | ១៥០ | ពីខែ០៤ ដល់ ខែ០៧ |
| ១៤ | មងត្រីកន្ដាំង | ម៉ែត្រ | ១៥០ | ពីខែ០៤ ដល់ ខែ០៧ |

**ទីតាំង ឬកន្លែងនេសាទ**

| ល.រ | ឈ្មោះទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | |
|---|---|---|---|---|
| | | | ប្រភេទ | ទំហំ/ប្រវែង |
| ១ | កន្លែងនេសាទសមុទ្រ ក្រៅពីកន្លែងអភិរក្ស | តាមប្រភេទត្រី | លប មង សន្ទូច ។ល។ | លេខ៣១៩ ប្រក.កសក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ |

**សំគាល់:** ត្រូវអនុវត្តតាមប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខ៣១៩ ប្រក.កសក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ ស្ដីពីការកំណត់ប្រភេទឧបករណ៍ដែលអនុញ្ញាតិឱ្យធ្វើនេសាទក្នុងដែននេសាទសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា។

**ឥ.២.ផែនការចុះល្បាត**

ជាទូទៅ ការចុះល្បាតជាភារកិច្ចរបស់គណៈកម្មការ និងសមាជិកសហគមន៍ ប៉ុន្តែ ការចុះល្បាតនេះគឺផ្អែកលើការជួយឧត្ថម្ភពីដៃគូអភិវឌ្ឍន៍។ កន្លងមក ការចុះល្បាតលើកន្លែងនេសាទសហគមន៍បានអនុវត្តតិចតួចពីព្រោះថា ខ្វះមធ្យោបាយល្បាត។ សហគមន៍នេសាទ បានរៀបចំផែនការល្បាតក្នុងគោលបំណងដូចជាៈ

- ទប់ស្កាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់
- សមាជិកអាចទទួលបានផលនេសាទពីកន្លែងនេសាទសហគមន៍
- គ្រប់គ្រងធនធានជលផលប្រកបដោយចីរភាព

ផែនការល្បាត ត្រូវបានរៀបចំឡើងដូចមានក្នុងតារាងខាងក្រោម៖

| លរ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(រៀល) | អ្នកចូលរួម | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ១ | ប្រជុំពិភាក្សាលើការរៀបចំផែនការល្បាត | ៥០០ ០០០ | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល | ២០២២ | ២០២៤ |
| ២ | រៀបចំមធ្យោបាយ និងសម្ភារៈ<br>• សាំង និងប្រេងបាត<br>• អាវភ្លៀង អាវពោង ពិល មួក<br>• កាតទូរស័ព្ទ អាយកូមទាក់ទង<br>• ទូកម៉ាស៊ីន | ៩ ០០០ ០០០ | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | ២០២២ | ២០២៤ |
| ៣ | ប្រជុំផ្សព្វផ្សាយផែនការល្បាត ដល់អ្នកពាក់ព័ន្ធ | ៥០០ ០០០ | ជំនាញជលផល អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ | ២០២២ | ២០២៤ |
| ៤ | អនុវត្តផែនការ និងកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន ជលផល និងជំនាញពាក់ព័ន្ធ | ៣ ៥០០ ០០០ | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល | ២០២២ | ២០២៤ |

**គ.៣.ផែនការរៀបចំកន្លែងអភិរក្ស**

សហគមន៍នេសាទ បានសម្រេចបង្កើតកន្លែងអភិរក្សចំនួន០៣កន្លែងគឺ ព្រៃកស្រមោច និងព្រៃកបឹងចាក និងកន្លែងអភិរក្សគ្រែងឈាមដែលជាកន្លែងមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជ ផ្កាថ្ម និងគ្រែងឈាម។ ដូចនេះ កន្លែងអភិរក្សបានធ្វើការគ្រប់គ្រងបន្ទាប់ពីសហគមន៍នេសាទ ត្រូវបានប្រកាសទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយកន្លែងអភិរក្សត្រីមេពូជទាំងពីរ នេះបង្កើតឡើងក្នុងគោលបំណងដូចជា៖

- បង្កើនពូជត្រី និងសត្វគ្រប់ប្រភេទ
- ថែរក្សាការពារព្រៃលិចទឹកដែលជាជម្រក ប្រភពចំណីរបស់ត្រី និងសត្វ
- ផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋឱ្យចេះស្រឡាញ់ថែរក្សា ការពារធនធានធម្មជាតិ
- ពិសេស ធនធានជលផល បរិស្ថាន និងចូលរួមលុបបំបាត់ការនេសាទខុសច្បាប់។

តាមការចុះអង្កេតរបស់ក្រុមការងារ និងពិភាក្សាលើលក្ខណៈវិនិច្ឆ័យជាមួយគណៈកម្មការ និងសមាជិកសហគមន៍នសាទនេះបានបញ្ជាក់ថា សហគមន៍នេសាទបានសម្រេចបង្កើតកន្លែងអភិរក្សគឺ កន្លែងអភិរក្សព្រៃកស្រមោចដែលមានទំហំ១០ហិកតា និងកន្លែងអភិរក្សព្រៃកបឹងចាកមានទំហំ៥០ហិកតា ដែលជាកន្លែងសំខាន់បំផុតសម្រាប់ធ្វើការអភិរក្សត្រីមេពូជផ្កាថ្ម និងក្រែមឈាមមានទំហំ០៥ហិកតា ដែលសមាជិសហគមន៍នេសាទមានសុច្ឆន្ទៈចង់ចូលរួមក្នុងការគ្រប់គ្រងធនធានជលផល ដើម្បីធានានូវប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានជលផល និងជាប្រយោជន៍សម្រាប់តម្រូវការផលត្រីរបស់ប្រជាពលរដ្ឋក្នុងសហគមន៍។ ដូចនេះ សហគមន៍នេសាទបានសម្រេចបង្កើតកន្លែងអភិរក្សចំនួន០៣កន្លែង ដូចបានបញ្ជាក់ក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះកន្លែងអភិរក្ស | ទំហំជាហត | ការអភិរក្ស |
|---|---|---|---|
| ១ | ព្រៃកស្រមោច | ១០ | ការអភិរក្សត្រីមេពូជផ្កាថ្ម |
| ២ | ព្រៃកបឹងចាក | ៥០ | ការអភិរក្សត្រីមេពូជផ្កាថ្ម |
| ៣ | កន្លែងអភិរក្សគ្រែងឈាម | ០៥ | ការអភិរក្សគ្រែងឈាម |

កន្លែងអភិរក្សត្រីមេពូជ ផ្កាថ្ម និងគ្រែងឈាម ជាកត្តាចាំបាច់ដែលត្រូវរៀបចំកំណត់ព្រំប្រទល់ បោះបង្គោលស៊ីម៉ងព្រំប្រទល់ ធ្វើប៉ាណូផ្សព្វផ្សាយ ក្ដាខៀនព័ត៌មាន បិទផ្សាយបទបញ្ញត្តិផ្សេងៗសម្រាប់កន្លែងអភិរក្ស សាងសង់រោងយាមសម្រាប់ក្រុមល្បាតបំពេញការងារ ។

ផែនការរៀបចំកន្លែងអភិរក្ស ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ឈ្មោះទីតាំង | ទំហំ (ហត) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| កន្លែងអភិរក្ស ព្រៃកស្រមោច និង ព្រៃកបឹងចាក | ៦០ | • ប្រភេទត្រីសំខាន់<br>• ប្រភេទផ្កាថ្ម<br>• ប្រភេទសារាយ<br>• ប្រភេទពពួកល្មូន | • ផ្សព្វផ្សាយអ្នកពាក់ព័ន្ធ<br>• សិក្សាពីកន្លែងអភិរក្ស<br>• បង្គោលស៊ីម៉ង់១២ដើម<br>•ធ្វើប៉ាណូផ្សព្វផ្សាយ<br>•សង់រោងយាម<br>•ចុះល្បាតជាប្រចាំ | ២០២២ | ២០២៤ |
| កន្លែងអភិរក្ស គ្រែងឈាម | ០៥ | ប្រភេទគ្រែងឈាម | • ផ្សព្វផ្សាយអ្នកពាក់ព័ន្ធ<br>• សិក្សាពីកន្លែងអភិរក្ស<br>• បង្គោលស៊ីម៉ង់០៦ដើម<br>•ធ្វើប៉ាណូផ្សព្វផ្សាយ<br>•ចុះល្បាតជាប្រចាំ | ២០២២ | ២០២៤ |

### គ.៤.ផែនការគ្រប់គ្រងព្រៃកោងកាង

ព្រៃកោងកាង បានគ្របដណ្តប់លើដែននេសាទសហគមន៍ដែលមានទំហំប្រហែល២៨០ហិកតា ដោយបានផ្តល់នូវសក្តានុពល និងសារៈប្រយោជន៍ជាច្រើនដល់ប្រភេទត្រីសត្វល្មូន ប្រភេទសត្វ និងវារីសត្វផ្សេងទៀតសម្រាប់ជាជម្រករស់នៅបង្កកំណើតជាកូន និងជាចំណីផងដែរ។ ដូចនេះ ផែនការគ្រប់គ្រងព្រៃកោងកាងក្នុងគោលបំណងដូចជា៖

- ថែរក្សា ការពារព្រៃកោងកាងឱ្យនៅគង់វង្សយូរអង្វែងដល់ក្មេងជំនាន់ក្រោយ។
- ទុកជាជម្រកត្រី វារីសត្វគ្រប់ប្រភេទ ជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ ទប់ស្កាត់ការហូរច្រោះទឹករលក និងជារបាំងខ្យល់។

- បង្កើនទិន្នផលត្រី និងពពួកសត្វមានជីវិតគ្រប់ប្រភេទឱ្យសំបូរឡើង ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍។

គណៈកម្មការ និងសមាជិកសហគមន៍នេសាទបានកំណត់ បែងចែកព្រៃកោងកាង កន្លែងអភិរក្ស និងកន្លែងប្រើប្រាស់ព្រៃកោងកាងដោយផ្អែកតាមផែនទីសហគមន៍នេសាទ។ កន្លែងប្រើប្រាស់ព្រៃកោងកាង ត្រូវអប់រំណែនាំដល់ប្រជាពលរដ្ឋឱ្យចេះកាប់រំលោះមែកដែលធ្វើយ៉ាងណាមិនឱ្យងាប់ដើម ដើម្បីយកមកប្រើប្រាស់ជាអុសចំអិនអាហារ។

ផែនការគ្រប់គ្រងព្រៃកោងកាង ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ឈ្មោះទីតាំង | ទំហំ ហត | ប្រភេទកូនឈើ ដែលត្រូវការពារ | សកម្មភាព | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ថែរក្សា និងការពារ ព្រៃកោងកាង | ២៨០ | ព្រៃកោងកាង | • ផ្សព្វផ្សាយផែនការគ្រប់គ្រងព្រៃកោងកាង<br>• បោះបង្គោល<br>• ដាក់ស្លាកសញ្ញាការពារ<br>• ត្រួតពិនិត្យ និងការពារ | ២០២២ | ២០២៤ |

### គ.៤.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ក្រៅពីនេសាទត្រី ការចិញ្ចឹមត្រីជាមុខរបរចំបងរបស់ប្រជានេសាទនៅក្នុងសហគន៍នេះ។ ជាទូទៅ ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទនេះ ច្រើនចិញ្ចឹមត្រី និងក្តាមថ្មដូចជា៖ ត្រីឆ្តុង និងក្តាមថ្ម។ល។ ការចិញ្ចឹមត្រីជាទម្លាប់របស់ប្រជាពលរដ្ឋកម្ពុជាជាយូរឆ្នាំមកហើយ ដោយអ្នកខ្លះចាប់បានពូជត្រីពីធម្មជាតិ អ្នកខ្លះទៀតចិញ្ចឹមដូចលក្ខណៈប្រស់ ឬចិញ្ចឹមបំប៉នឱ្យមានទំហំសមស្របសម្រាប់តម្រូវការទីផ្សារ។

ការចិញ្ចឹមត្រីជាទិសដៅដ៏សំខាន់របស់វិស័យជលផល ក្នុងការបង្កើនត្រីសាច់សម្រាប់ហូបចុករបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងសម្រាប់នាំចេញទៅទីផ្សារអន្តរជាតិ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឱ្យមានការរីកចំរើន។ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចេញប្រកាសលេខ៣២៥ប្រក កសកស្តីពី ការគ្រប់គ្រងការចិញ្ចឹមត្រីរ៉ស់ ត្រីឆ្តោរដែលស្របនឹងតម្រូវការប្រជាពលរដ្ឋនៅមូលដ្ឋាន។ ដូចនេះផងដែរ សហគមន៍នេសាទនេះ បានផ្តោតសំខាន់លើការចិញ្ចឹមត្រីមានដូចជា ការចិញ្ចឹមត្រីទឹកសាប ការចិញ្ចឹមត្រីត្រីឆ្តុង និងក្តាមថ្ម ពីព្រោះសហគមន៍នេះស្ថិតជាប់នឹងសមុទ្រ។ ការអភិវឌ្ឍន៍វារីវប្បកម្មរបស់សហគមន៍នេសាទ ក្នុងគោលបំណង៖

- បង្កើនត្រីសាច់សម្រាប់ហូបចុករបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- បង្កើនប្រាក់ចំណូលដែលជួយស្ទួយសេដ្ឋកិច្ចគ្រួសារ
- កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត។

ឆ្លើយតបទៅនឹងការពង្រីកការអភិវឌ្ឍន៍វារីវប្បកម្ម គណៈកម្មការ និងសមាជិកសហគមន៍នេសាទនេះបានរៀបចំផែនការអភិវឌ្ឍន៍វារីវប្បកម្ម ដូចមានក្នុងតារាងខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | ប្រភេទកូនត្រី | បរិមាណកូនត្រី | ថ្ងៃ/ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | ប្រមូលផល |
| ចិញ្ចឹមត្រីឆ្តុងតាមបច្ចេកទេសជាលក្ខណៈគ្រួសារក្នុងបែចំនួន២០គ្រួសារ | • ជ្រើសរើសសមាជិក<br>• បច្ចេកទេសចិញ្ចឹម<br>• ធ្វើបែចិញ្ចឹម<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | ២០បែ | កូនត្រីឆ្តុង | ៥០០/គ្រួសារ | ២០២២ | ២០២៤ |
| ចិញ្ចឹមក្តាមថ្ម តាមបច្ចេកទេសជាលក្ខណៈគ្រួសារចំនួន០៦គ្រួសារ | • ជ្រើសរើសសមាជិក<br>• បច្ចេកទេសចិញ្ចឹម<br>• ធ្វើកន្លែងចិញ្ចឹម<br>• ផ្តល់កូន<br>• តាមដានត្រួតពិនិត្យ | ទំហំដី១០ អា/គ្រួសារ | កូនក្តាមថ្ម | ៩០០កូន/គ្រួសារ | ២០២២ | ២០២៤ |

**គ.៦.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទ**

ពេលបច្ចុប្បន្ន សហគមន៍នេសាទ បានរៀបចំផែនការកន្លែងកំសាន្តនៅកន្លែងមាត់សមុទ្រដែលជាដែននេសាទរបស់សហគមន៍នេសាទ ដែលអាចជួយកាត់បន្ថយអត្រាចំណាកស្រុករបស់សមាជិកសហគមន៍នេសាទ និងកាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯងសម្រាប់ក្នុងការចូលរួមចំណែកក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តភាព។ ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍ក្នុងគោលបំណងដូចជា៖

- បង្កើនប្រាក់ចំណូលដែលជួយស្ទួយសេដ្ឋកិច្ចគ្រួសារ
- ជួយកាត់បន្ថយអត្រាចំណាកស្រុករបស់សមាជិកសហគមន៍នេសាទ
- កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត
- កាត់បន្ថយអត្រាការប្រាក់ខ្ពស់ និងខ្ចីប្រាក់ពីឈ្មួញ
- ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង។

ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍ ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ប្រភពថវិកា | ថ្ងៃ/ខែ/ឆ្នាំចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំបញ្ចប់ |
|---|---|---|---|---|
| រៀបចំកន្លែងកំសាន្តសហគមន៍នេសាទ | • ផ្សព្វផ្សាយទស្សនៈដល់សមាជិក<br>• ការរៀបចំក្រុមសម្រាប់អនុវត្ត<br>• បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង<br>• បណ្តុះបណ្តាលពីឯកសារថវិកា<br>• ត្រួតពិនិត្យតាមដាន | គាំទ្រដោយដៃគូរអភិវឌ្ឍន៍ | ២០២២ | ២០២៤ |

### គ.៧.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ

ជាទូទៅ បេក្ខជនដែលឈរឈ្មោះជាគណៈកម្មការសហគមន៍នេសាទត្រូវបានបញ្ជាក់ពីគុណភាព និងចំណេះដឹងដូចជា៖ចេះអាន សរសេរ អាកប្បកិរិយាសមរម្យដោយឯកភាពពីសមាជិកសហគមន៍ ហើយការរៀបចំបោះឆ្នោតជ្រើសរើសជាគណៈកម្មការ បានប្រើនីតិវិធីស្របតាមគោលការណ៍ណែនាំសហគមន៍នេសាទដែលបានអនុម័តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ជាក់ស្តែង គណៈកម្មការសហគមន៍នេសាទ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោត ដោយត្រឹមត្រូវ និងយុត្តិធម៌ដែលមានសំឡេងគាំទ្រច្រើនជាងគេ ហើយញឹកញាប់សមាសភាពគណៈកម្មការសហគមន៍នេសាទគឺ ថ្មីដែលសមត្ថភាពរបស់សមាជិកគណៈកម្មការមានកំរិតលើការយល់ដឹងពីលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុង ជំនាញសម្របសម្រួលទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ និងការរៀបចំផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ។ ដូចនេះ ផែនការបណ្តុះបណ្តាលដល់សមាសភាពគណៈកម្មការសហគមន៍នេសាទ នឹងត្រូវបានរៀបចំក្នុងគោលបំណង៖

- គណៈកម្មការសហគមន៍នេសាទនឹងអាចអនុវត្តសកម្មភាពក្នុងការងារ
- យល់ពីតួនាទី និងភារកិច្ចរបស់ពួកគាត់
- បង្កើនសាមគ្គីភាព និងការទំនាក់ទំនងល្អជាមួយសហគមន៍ និងអ្នកពាក់ព័ន្ធ។

ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍ ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| លរ | សកម្មភាព | ចំនួន | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| ១ | បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ សរសេរលិខិត រដ្ឋបាលរបាយការណ៍ និងរៀបចំទុកឯកសារ | ១លើក | ២០២២ | ២០២២ |
| ២ | បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | ១លើក | ២០២២ | ២០២២ |
| ៣ | បណ្តុះបណ្តាលការដោះស្រាយទំនាស់ | ១លើក | ២០២៣ | ២០២៣ |
| ៤ | បណ្តុះបណ្តាលជំនាញក្នុងការសម្របសម្រួល | ១លើក | ២០២៣ | ២០២៣ |
| ៥ | បណ្តុះបណ្តាលការរៀបចំផែនការ | ១លើក | ២០២៤ | ២០២៤ |

### គ.៨.ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ

ពេលបច្ចុប្បន្ន ធនធានជលផលក្នុងសហគមន៍កំពុងទទួលរងនូវការគំរាមកំហែងពីអ្នកខាងក្នុង និងខាងក្រៅ ដោយការកាប់រានព្រៃលិចទឹក និងការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់។ ដូចនេះ ដើម្បីធានាការប្រើប្រាស់ធនធានជលផលពេលអនាគត និងបានយូរអង្វែងនោះ តម្រូវធ្វើការផ្សព្វផ្សាយអំពីច្បាប់ស្តីពី ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដើម្បីឱ្យមានការយល់ដឹងគ្រប់គ្រាន់ និងចូលរួមចំណែកក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តភាព។ គោលបំណងនៃការផ្សព្វផ្សាយមានដូចខាងក្រោម៖

- បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋក្នុងសហគមន៍
- កាត់បន្ថយសកម្មភាពបទល្មើសនេសាទក្នុងសហគមន៍

ផែនការផ្សព្វផ្សាយពីច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| សកម្មភាព | អ្នកទទួលខុសត្រូវ | រយៈពេលអនុវត្ត ២០២២-២០២៤ | | | តម្លៃប៉ាន់ស្មាន (រៀល ) | ប្រភពទុន |
|---|---|---|---|---|---|---|
| | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | | |
| ផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ | រដ្ឋបាលជលផល | ៤ | ៤ | ៤ | ១ ៥០០ ០០០ | រដ្ឋបាលជលផល ដៃគូអភិវឌ្ឍន៍ រដ្ឋបាលឃុំ |
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង | ស.ន | ៤ | ៤ | ៤ | ១ ០០០ ០០០ | រដ្ឋបាលជលផល ដៃគូអភិវឌ្ឍន៍ រដ្ឋបាលឃុំ |

**គ.៩.ផែនការបង្កើតស្នាក់ការ និងការបំពាក់សម្ភារៈ**

ពេលបច្ចុប្បន្ន សហគមន៍នេសាទនេះពុំទាន់មានស្នាក់ការនៅឡើយ ហើយគណៈកម្មការមានការលំបាកក្នុងពេលបំពេញការងារក៏ដូចជា ការងារទំនាក់ទំនងជាមួយក្រុមការងារផ្សេងៗ ឬភ្ញៀវទេសចរណ៍ជាដើម។ ដូច្នេះ ស្នាក់ការ និងការបំពាក់សម្ភារៈមួយចំនួនដូចជា៖ តុ កៅអី និងទូឯកសារ។

ផែនការបង្កើតស្នាក់ការ ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | សកម្មភាព | ទីតាំងគម្រោង | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ | តម្លៃប៉ាន់ស្មាន (រៀល) | ប្រភពទុន |
|---|---|---|---|---|---|---|
| ១ | គម្រោងស្នាក់ការ | ស.ន | ២០២២ | ២០២៤ | ១១ ០០០ ០០០ | អង្គការដៃគូ សប្បុរសជន |
| ២ | ការបំពាក់សម្ភារៈ | ស.ន | ២០២២ | ២១២៤ | ៤ ០០០ ០០០ | |

**គ.១០.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ**

ដោយឡែក គណៈកម្មការសហគមន៍នេសាទ ត្រូវដើរតួនាទីសំខាន់ក្នុងការស្វែងរកប្រាក់ចំណូលពីប្រភពផ្សេងៗដូចជា៖ វិភាគទានពីសមាជិកសហគមន៍ អង្គការដៃគូអភិវឌ្ឍន៍ សប្បុរសជន ក្រុមប្រឹក្សាឃុំ និងការធ្វើទស្សនៈកិច្ចរបស់ភ្ញៀវមកក្នុងសហគមន៍នេសាទ។

ដូចនេះ ផែនការស្វែងរកថវិកា ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ប្រភេទចំណូល | សកម្មភាព | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ | ចំណូល (រៀល) |
|---|---|---|---|---|---|
| ១ | វិភាគទានប្រចាំឆ្នាំពីសមាជិកសហគមន៍ | ប្រជុំផ្សព្វផ្សាយនិងបណ្ណវិភាគទាន | ២០២២ | ២០២៤ | ១ ៥០០ ០០០ |
| ២ | ពីអ្នកនេសាទខាងក្រៅ ឬអ្នកមិនមែនជាសមាជិក | ចេញបណ្ណវិភាគទាន | ២០២២ | ២០២៤ | ២ ៥០០ ០០០ |
| ៣ | សប្បុរសជន និង អង្គការដៃគូអភិវឌ្ឍន៍ | • បង្កើតមុតរបរ<br>• ជាថវិកាផ្ទាល់ | ២០២២ | ២០២៤ | ៣ ៥០០ ០០០ |
| ៤ | ក្រុមប្រឹក្សាឃុំ | ធនធានធម្មជាតិ | ២០២២ | ២០២៤ | ១ ៥០០ ០០០ |

### ឃ.យុទ្ធសាស្ត្រ

នៅក្នុងសហគមន៍នេសាទ ត្រូវបានរៀបចំយុទ្ធសាស្ត្រ ដើម្បីឱ្យការអនុវត្តផែនការទទួលបានជោគជ័យ។ យុទ្ធសាស្ត្រទាំងនេះមានដូចខាងក្រោម៖

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការរួមមាន៖ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទដែលមានបទពិសោធន៍ និងចំណេះដឹងល្អជាពិសេសអំពីបញ្ហានេសាទ។
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា៖ ការធ្វើផែនការកន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងអភិរក្សព្រៃកោងកាង កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទការចិញ្ចឹមត្រី ការស្វែងរកថវិកាសម្រាប់ទ្រទ្រង់សហគមន៍នេសាទជាដើម។
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ ដៃគូអភិវឌ្ឍន៍នានា និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ។
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់។
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូអភិវឌ្ឍន៍សម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ។
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ។
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ។
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍។
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ។
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ។
- បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

# តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍បន្ទាយប្រិយក្នុងរយៈពេល០៣ឆ្នាំ (ខែកុម្ភៈ ឆ្នាំ២០២២- ខែធ្នូ ឆ្នាំ២០២៤)

| ប្រភេទផែនការ/សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (រៀល) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ |
|---|---|---|---|---|---|
| **១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ** | • កាត់បន្ថយទំនាស់នេសាទក្នុងកន្លែងនេសាទ<br>• កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់<br>• សហគមន៍នឹងអនុវត្តន៍ប្រកាសស្តីពីការប្រើប្រាស់ឧបករណ៍ | ១ ៩០០ ០០០ | | ២០២២ | ២០២៤ |
| ១.១.ប្រជុំផ្សព្វផ្សាយការប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារក្នុង១ឆ្នាំ/៤ដង | សមាជិកនឹងយល់ដឹងពីការការប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារ | ១ ៩០០ ០០០ | អង្គការដៃគូ សប្បុរសជន រដ្ឋាភិបាល | | |
| ១.២.ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | ឧបករណ៍នេសាទ នឹងត្រូវបានផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | | | | |
| ១.៣.ត្រួតពិនិត្យ និងតាមដាន | គណៈកម្មការ និងសមាជិកចូលរួមឃ្លាំមើល និងរាយការណ៍ | | | | |
| **២.ផែនការចុះល្បាត** | •ទប់ស្កាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់<br>•សមាជិកអាចទទួលបានផលនេសាទពីកន្លែងនេសាទសហគមន៍<br>•គ្រប់គ្រងធនធានជលផលប្រកបដោយចីរភាព | **១៣ ៥០០ ០០០** | | | |
| ២.១.ប្រជុំពិភាក្សាលើការរៀបចំផែនការល្បាត | ផែនការល្បាតនឹងបានពិគ្រោះយោបល់ ដើម្បីរៀបចំសម្រាប់អនុវត្ត | ៥០០ ០០០ | | ២០២២ | ២០២៤ |
| ២.២.រៀបចំមធ្យោបាយ និងសម្ភារៈ | មធ្យោបាយ និងសម្ភារៈបានគ្រោង និងរៀបចំ | ៩ ០០០ ០០០ | | | |
| ២.៣.ប្រជុំផ្សព្វផ្សាយផែនការល្បាតដល់អ្នកពាក់ព័ន្ធ | ផែនការល្បាតត្រូវបានផ្សព្វផ្សាយ | ៥០០ ០០០ | | | |
| ២.៤.អនុវត្តផែនការចុះល្បាត | ផែនការចុះល្បាតត្រូវបានចុះអនុវត្ត | ៣ ៥០០ ០០០ | | | |
| **៣.ផែនការរៀបចំកន្លែងអភិរក្ស** | •ប្រភេទត្រីមេពូជ និងវារីសត្វគ្រប់ប្រភេទត្រូវបានធ្វើការអភិរក្ស<br>•ប្រភេទព្រៃកោងកាងនឹងត្រូវបានការពារ<br>•ប្រជាជននឹងយល់ដឹងពីសារៈសំខាន់កន្លែងអភិរក្ស នឹងចូលរួមថែរក្សា | **៩ ០០០ ០០០** | | | |
| ៣.១.បោះបង្គោលស៊ីម៉ង់កន្លែងអភិរក្សព្រែកស្រមោច ព្រែកបឹងចាក និងកន្លែងអភិរក្សក្រែមឈាម | ចំនួន០៨បង្គោលនឹងបានបោះនៅកន្លែងអភិរក្សទាំងពីរដោយមានផែនទីសំគាល់កន្លែងអភិរក្ស | ៤ ៥០០ ០០០ | | | |
| ៣.២.ផ្សព្វផ្សាយដល់ប្រជាជន | ប្រជាជននឹងយល់ដឹងពីសារៈប្រយោជន៍កន្លែងអភិរក្ស | ៥០០ ០០០ | អង្គការដៃគូ សប្បុរសជន រដ្ឋាភិបាល | ២០២២ | ២០២៤ |
| ៣.៣.ផលិតផ្ទាំងប៉ាណូផ្សព្វផ្សាយ | ចំនួន០១ស្លាកផ្ទាំងប៉ាណូ នឹងបោះក្នុងទីតាំងសម្រាប់ផ្សព្វផ្សាយ | ១ ២០០ ០០០ | | | |
| ៣.៤.សង់រោងយាម | រោងយាមចំនួន០១ត្រូវបានសាងសងនៅកន្លែងអភិរក្សទំហំ៤មx៥ម | ១ ៨០០ ០០០ | | | |
| ៣.៥.ចុះល្បាតជាប្រចាំ | ការចុះល្បាតនឹងត្រូវបានអនុវត្ត | ១ ០០០ ០០០ | | | |
| **៤.ផែនការគ្រប់គ្រងព្រៃកោងកាងទំហំ ២៨០ហិកតា** | • សមាជិកសហគមន៍យល់ដឹងពីសារៈប្រយោជន៍ព្រៃកោងកាង<br>• ព្រៃកោងកាងត្រូវបានការពារដោយសមាជិកសហគមន៍នេសាទ | **២ ០០០ ០០០** | | | |

| | | | | | |
|---|---|---|---|---|---|
| ៤.១.ប្រជុំផ្សព្វផ្សាយពីសារៈប្រយោជន៍ព្រៃកោងកាង | សមាជិកសហគមន៍យល់ដឹងពីសារៈប្រយោជន៍ព្រៃកោងកាង | ២០០ ០០០ | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០២២ | ២០២៤ |
| ៤.២.ថែរក្សា និងការពារព្រៃកោងកាង | អ្នកពាក់ព័ន្ធនឹងចូលរួមថែរក្សា និងការពារព្រៃកោងកាង | ៨០០ ០០០ | | | |
| ៤.៣.ចុះល្បាតជាប្រចាំ | សកម្មភាពកាប់បំផ្លាញព្រៃកោងកាង នឹងត្រូវបានទប់ស្កាត់ | ១ ០០០ ០០០ | | | |
| **៥.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម** | • បង្កើនត្រីសាច់សម្រាប់ហូបចុកក្នុងមូលដ្ឋាន<br>• រកប្រាក់ចំណូលជួយស្តួយសេដ្ឋកិច្ចគ្រួសារ<br>• កាត់បន្ថយសម្ពាធនេសាទលើធនធានជលផលហួសកំរិត។ | **១០ ០០០ ០០០** | | | |
| **៥.១.ចិញ្ចឹមត្រីឆ្តុងតាមបច្ចេកទេសជាលក្ខណៈគ្រួសារក្នុងបែចំនួន២០គ្រួសារ** | | **៣ ០០០ ០០០** | | | |
| ៥.១.១.ជ្រើសរើសសមាជិកសហគមន៍ | សមាជិកសហគមន៍ចំនួន២០គ្រួសារត្រូវបានជ្រើសរើស | ៣ ០០០ ០០០ | ដៃគូរអភិវឌ្ឍន៍<br>សប្បុរសជន<br>រដ្ឋាភិបាល | ២០២២ | ២០២៤ |
| ៥.១.២.បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីឆ្តុង | ចំនួន២០គ្រួសារ នឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីឆ្តុង | | | | |
| ៥.១.៣.ធ្វើបែចិញ្ចឹមត្រីឆ្តុង | ចំនួន២០បែ ដែលក្នុង១បែមានទំហំ៥ម x៣មx២,៥ម ត្រូវបានសាងសង់ | | | | |
| ៥.១.៤.ការដាក់កូនត្រីក្នុងបែ | ចំនួនកូនត្រី៥០០កូននឹងត្រូវបានផ្តល់ក្នុងមួយគ្រួសារ | | | | |
| ៥.១.៥.ត្រួតពិនិត្យតាមដាន | សមាជិកសហគមន៍ចំនួន២០គ្រួសារ នឹងត្រូវបានធ្វើការត្រួតពិនិត្យ | | | | |
| **៥.២.ចិញ្ចឹមក្តាមថ្មតាមបច្ចេកទេសជាលក្ខណៈគ្រួសារចំនួន០៦គ្រួសារ** | | **៧ ០០០ ០០០** | | | |
| ៥.២.១.ជ្រើសរើសសមាជិកសហគមន៍ | សមាជិកសហគមន៍ចំនួន០៦គ្រួសារត្រូវបានជ្រើសរើស | ៧ ០០០ ០០០ | ដៃគូរអភិវឌ្ឍន៍<br>សប្បុរសជន<br>រដ្ឋាភិបាល | ២០២២ | ២០២៤ |
| ៥.២.២.បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមក្តាមថ្ម | ចំនួន០៦គ្រួសារ នឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមក្តាមថ្ម | | | | |
| ៥.២.៣.រៀបចំកន្លែងចិញ្ចឹមក្តាមថ្ម | ចំនួន០៦គ្រួសារ ដែលក្នុង១គ្រួសារមានទំហំដី១០អា ត្រូវបានរៀបចំ | | | | |
| ៥.២.៤.ការដាក់កូនក្តាមថ្ម | ចំនួនកូនក្តាមថ្ម៥០០កូន នឹងត្រូវបានផ្តល់ក្នុងមួយគ្រួសារ | | | | |
| ៥.២.៥.ត្រួតពិនិត្យតាមដាន | សមាជិកសហគមន៍ចំនួន០៦គ្រួសារ នឹងត្រូវបានធ្វើការត្រួតពិនិត្យ | | | | |
| **៦.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទ** | • បង្កើនប្រាក់ចំណូលដែលជួយស្តួយសេដ្ឋកិច្ចគ្រួសារ<br>• កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត<br>• ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួន | **១១ ០០០ ០០០** | | | |
| ៦.១.ផ្សព្វផ្សាយទស្សនៈដល់សមាជិកសហគមន៍ | ទស្សនៈទាននឹងផ្សព្វផ្សាយដល់សមាជិកសហគមន៍ | ១១ ០០០ ០០០ | ដៃគូរអភិវឌ្ឍន៍<br>សប្បុរសជន<br>រដ្ឋាភិបាល | ២០២២ | ២០២៤ |
| ៦.២.បង្កើតក្រុមសម្រាប់អនុវត្ត | ក្រុមរៀបចំកន្លែងកំសាន្តសហគមន៍នឹងត្រូវបានបង្កើត | | | | |
| ៦.៣.រៀបចំគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង | គោលការណ៍ និងបទបញ្ជាផ្ទៃក្នុងនឹងត្រូវបានរៀបចំ | | | | |
| ៦.៤.បណ្តុះបណ្តាលពីការរៀបចំឯកសារ និងថវិកា | ឯកសារ ថវិកានឹងបានបណ្តុះបណ្តាល | | | | |
| ៦.៥.ត្រួតពិនិត្យតាមដាន | ក្រុមរៀបចំកន្លែងកំសាន្តនឹងធ្វើការត្រួតពិនិត្យនិងកែលម្អ | | | | |

| | | | | | |
|---|---|---|---|---|---|
| **៧.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ** | • គណៈកម្មការនឹងអាចអនុវត្តសកម្មភាពក្នុងការងារ<br>• យល់ពីតួនាទីនិងភារកិច្ចរបស់ពួកគាត់<br>• បង្កើនសាមគ្គីភាពនិងការទំនាក់ទំនងល្អជាមួយអ្នកពាក់ព័ន្ធ | **១ ៧០០ ០០០** | | | |
| ៧.១.បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ សរសេររបាយការណ៍ និងលិខិតរដ្ឋបាល | កំណត់ហេតុ សរសេររបាយការណ៍ និងលិខិតរដ្ឋបាលនឹងត្រូវបានបណ្តុះបណ្តាល | ៤០០ ០០០ | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០២២ | ២០២២ |
| ៧.២.បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | ការគ្រប់គ្រងថវិកា នឹងត្រូវបានបណ្តុះបណ្តាល | ៣០០ ០០០ | | ២០២២ | ២០២២ |
| ៧.៣.បណ្តុះបណ្តាលការដោះស្រាយទំនាស់ | វិធីសាស្ត្រដោះស្រាយទំនាស់នឹងត្រូវបានបណ្តុះបណ្តាល | ៤០០ ០០០ | | ២០២២ | ២០២២ |
| ៧.៤.បណ្តុះបណ្តាលជំនាញក្នុងការសម្របសម្រួល | ជំនាញសម្របសម្រួលនឹងត្រូវបានបណ្តុះបណ្តាល | ២០០ ០០០ | | ២០២៣ | ២០២៣ |
| ៧.៥.បណ្តុះបណ្តាលការរៀបចំផែនការ | ការរៀបចំផែនការ នឹងត្រូវបានបណ្តុះបណ្តាល | ៤០០ ០០០ | | ២០២៤ | ២០២៤ |
| **៨.ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ** | • បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ<br>• កាត់បន្ថយសកម្មភាពបទល្មើសនេសាទ | **២ ៥០០ ០០០** | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០២២ | ២០២៤ |
| ៨.១.ផ្សព្វផ្សាយពីច្បាប់ជលផល និងបទដ្ឋានពាក់ព័ន្ធ | សមាជិកសហគមន៍នឹង ផ្សព្វផ្សាយពីច្បាប់ជលផលនិងលិខិតបទដ្ឋាន | ១ ៥០០ ០០០ | | | |
| ៨.២.ផ្សព្វផ្សាយលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង | សមាជិកសហគមន៍នឹងត្រូវបានផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង | ១ ០០០ ០០០ | | | |
| **៩.ផែនការបង្កើតស្នាក់ការ និងការបំពាក់សម្ភារៈ** | | **១៥ ០០០ ០០០** | | | |
| ៩.១.បង្កើតស្នាក់ការ | ស្នាក់ការរបស់សហគមន៍នឹងត្រូវបានជួសជុល | ១១ ០០០ ០០០ | អង្គការដៃគូ<br>សប្បុរសជន | ២០២២ | ២០២៤ |
| ៩.២.ការបំពាក់សម្ភារៈ | សម្ភារៈកៅអី និងទូឯកសានឹងត្រូវបានបំពាក់ | ៤ ០០០ ០០០ | | | |
| **១០.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍** | | **៩ ០០០ ០០០** | | | |
| ១០.១.វិភាគទានប្រចាំឆ្នាំពីសមាជិកសហគមន៍ | វិភាគទានប្រចាំឆ្នាំពីសមាជិកសហគមន៍ | ១ ៥០០ ០០០ | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០២២ | ២០២៤ |
| ១០.២.ពីអ្នកនេសាទខាងក្រៅឬអ្នកមិនមែនជាសមាជិក | ពីអ្នកនេសាទខាងក្រៅឬអ្នកមិនមែនជាសមាជិក | ២ ៥០០ ០០០ | | | |
| ១០.៣. អំណោយពីសប្បុរសជន និងអង្គការដៃគូ | សប្បុរសជន និងអង្គការដៃគូអភិវឌ្ឍន៍ | ៣ ៥០០ ០០០ | | | |
| ១០.៤.ក្រុមប្រឹក្សាឃុំ | មូលនិធិរបស់ឃុំ | ១ ៥០០ ០០០ | | | |

# តារាងកម្មវិធីការងារសម្រាប់សហគមន៍នេសាទបន្ទាយប្រិយក្នុងរយៈពេល០៣ឆ្នាំ (ខែកុម្ភៈ ឆ្នាំ២០២២- ខែធ្នូ ឆ្នាំ២០២៤)

| សកម្មភាព | ២០២២ | | | | | | | | | | | ២០២៣ | | | | | | | | | | | | ២០២៤ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ខែនីមួយៗ | | | | | | | | | | | ខែនីមួយៗ | | | | | | | | | | | | ខែនីមួយៗ | | | | | | | | | | | |
| | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| ១.ការប្រើប្រាស់ឧបករណ៍នេសាទក្នុងដែននេសាទសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២.ផែនការចុះល្បាត | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣.ផែនការរៀបចំកន្លែងអភិរក្ស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៤.ផែនការគ្រប់គ្រងព្រៃកោងកាង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.ផែនការពង្រឹងសមត្ថភាពគណៈកម្មការនិងសមាជិក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៨.ផែនការផ្សព្វផ្សាយច្បាប់ផលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៩.ផែនការបង្កើតស្នាក់ការសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១០.ការកថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

## តារាងកម្មវិធីការងារសម្រាប់សហគមន៍នេសាទបន្ទាយប្រិយក្នុងរយៈពេល០៣ឆ្នាំ (ខែកុម្ភៈ ឆ្នាំ២០២២- ខែធ្នូ ឆ្នាំ២០២៤)

| សកម្មភាព | ២០២២ | | | | | | | | | | | ២០២៣ | | | | | | | | | | | | ២០២៤ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ខែនីមួយៗ | | | | | | | | | | | ខែនីមួយៗ | | | | | | | | | | | | ខែនីមួយៗ | | | | | | | | | | | |
| | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| ១.ការប្រើប្រាស់ឧបករណ៍នេសាទក្នុងដែននេសាទសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ២.ផែនការចុះល្បាត | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ៣.ផែនការរៀបចំកន្លែងអភិរក្ស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ៤.ផែនការគ្រប់គ្រងព្រៃកោងកាង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ៥.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ៦.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ៧.ផែនការពង្រឹងសមត្ថភាពគណៈកម្មការនិងសមាជិក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ៨.ផែនការផ្សព្វផ្សាយច្បាប់ផលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ៩.ផែនការបង្កើតស្នាក់ការសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ១០.ការកថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |

សូមគោរពជូន
លោកចៅសង្កាត់អណ្តូងថ្ម
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ.........ខែ.........ឆ្នាំឆ្លូវត្រីស័ក,ព.ស២៥៦៥
.........ថ្ងៃទី.........ខែ.........ឆ្នាំ២០២១
**ប្រធានគណៈកម្មការសហគមន៍នេសាទ**
**បន្ទាយប្រិយ**

លេខ:.........
បានឃើញ និង គោរពជូន
លោកនាយសង្កាត់រដ្ឋបាលជលផលកំពង់ស្មាច់
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ.........ខែ.........ឆ្នាំឆ្លូវត្រីស័ក,ព.ស២៥៦៥
ថ្ងៃទី.........ខែ.........ឆ្នាំ២០២១
**មេឃុំ**

បានឃើញ និង គោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលព្រៃនប់
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ.........ខែ.........ឆ្នាំឆ្លូវត្រីស័ក,ព.ស២៥៦៥
ថ្ងៃទី.........ខែ.........ឆ្នាំ២០២១
**នាយសង្កាត់រដ្ឋបាលជលផលកំពង់ស្មាច់**

បានឃើញ និង គោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលកំពង់សោម
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ.........ខែ.........ឆ្នាំឆ្លូវត្រីស័ក,ព.ស២៥៦៥
ថ្ងៃទី.........ខែ.........ឆ្នាំ២០២១
**នាយផ្នែករដ្ឋបាលជលផលព្រៃនប់**

លេខ:.........
បានឃើញ និង គោរពជូន
លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះសីហនុ
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃ.........ខែ.........ឆ្នាំឆ្លូវ ត្រីស័ក,ព.ស២៥៦៥
.........ថ្ងៃទី.........ខែ.........ឆ្នាំ ២០២១
**នាយខណ្ឌរដ្ឋបាលជលផលកំពង់សោម**

លេខ.........
បានឃើញ និង គោរពជូន
ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល
ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ
ថ្ងៃ.........ខែ.........ឆ្នាំឆ្លូវត្រីស័ក,ព.ស២៥៦៥
.........ថ្ងៃទី.........ខែ.........ឆ្នាំ ២០២១
**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រះសីហនុ**
**អនុប្រធាន**
**គីក_ជីវ៉ាយ**

លេខ.........
បានឃើញ និងឯកភាព
ថ្ងៃ.........ខែ.........ឆ្នាំឆ្លូវត្រីស័ក,ព.ស២៥៦៥
រាជធានីភ្នំពេញ .ថ្ងៃទី.........ខែ.........ឆ្នាំ២០...
**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**
**ពុំ សុថា**